**វេទិកាសាធារណៈ**

**ស្តីអំពី**

**"អំពើហិង្សាក្នុងគ្រួសារ និងផលប៉ះពាល់លើវិស័យសេដ្ឋកិច្ច"**
**នាថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០១៤ នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ**

## សេចក្តីផ្តើម

ច្បាប់ស្តីអំពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ត្រូវបានអនុម័តកាលពីថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣។ ច្បាប់នេះមានគោលបំណងទប់ ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការពារជនរងគ្រោះ និងពង្រឹងវប្បធម៌អហិង្សា និងភាពសុខដុមរមនាក្នុងគ្រួសារ ក្នុងសង្គមនៅព្រះរាជាណាចក្រកម្ពុជា។

យ៉ាងណាក៏ដោយ របាយការណ៍ចុងក្រោយរបស់អង្គការ សហប្រជាជាតិ ចេញផ្សាយកាលពី ខែកញ្ញា ឆ្នាំ២០១៣ បានបង្ហាញថា បុរសកម្ពុជា១នាក់ក្នុងចំណោម៥នាក់បាននិយាយថា ពួកគេធ្លាប់បានប្រព្រឹត្ត អំពើហិង្សាតាមផ្លូវភេទ ទៅលើដៃគូស្និតស្នាលរបស់ពួកគេ ហើយប្រមាណ ១៦%នៃអ្នកប្រព្រឹត្តការរំលោភផ្លូវ ភេទនោះជាលើកដំបូងនៅពេល ពួកគេមានអាយុ ១៤ឆ្នាំ រឺក្មេងជាងនេះ។[1] អំពីហិង្សាក្នុងគ្រួសារជះឥទ្ធិពល យ៉ាងខ្លាំងទៅលើសេដ្ឋកិច្ចក្នុងគ្រួសារ និងប្រទេសទាំងមូល។ តាមរយៈរបាយការណ៍របស់អង្គការសុខភាព ពិភពលោកបានបង្ហាញ ឲ្យឃើញថាអ្នករងគ្រោះអំពើហិង្សាបានចំនាយថវិកាច្រើនទៅលើថ្លៃព្យាបាលសុខភាព ទាំងផ្លូវកាយ និងផ្លូវចិត្ត ការខកខានមិនបានធ្វើការដែលអាចនឹងបណ្តាលឲ្យមានការបាត់បង់ការងារ និងការចំនាយធ្វើការប្តឹងផ្តល់ជាដើម។[2] ទាំងអស់នេះអាចធ្វើឲ្យមានការខាតបង់ដល់ថវិកាប្រទេសជាតិទាំងមូលផងដែរ។

យោងតាមការបកស្រាយខាងលើ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) និងអង្គការយេនឌ័រ និង អភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) ក្រោមកិច្ចគាំទ្រថវិកាពីទីភ្នាក់ងារអេស្ប៉ាញដើម្បី សហប្រតិបត្តិការ អភិវឌ្ឍន៍ អន្តរជាតិ តាមរយៈអង្គការPYD បានរៀបចំវេទិកាសាធារណៈស្តីអំពី **"អំពើហិង្សាក្នុងគ្រួសារ និងផលប៉ះពាល់ លើវិស័យសេដ្ឋកិច្ច"** ដើម្បីផ្តល់នូវទេវិកាជូននិស្សិត និងមហាជន ចូលរួមស្វែងយល់ និងចែករំលែកអំពីបទ ពិសោធន៍ ទាក់ទងនឹងអំពើហិង្សាគ្រួសារ ផលប៉ះពាល់លើវិស័យសេដ្ឋកិច្ច និងការទប់ស្កាត់។

[1] Simon Henderson, UN Report Says 1 in 5 Cambodian Men Have Raped, September 11, 2013
[2] Heise L, Garcia-Moreno C (2002). Intimate partner violence. In: Krug et al., eds. World report on violence and health. Geneva, World Health Organization.

## គោលបំណង

វេទិកាសាធារណៈស្តីអំពី **"អំពើហិង្សាក្នុងគ្រួសារ និងផលប៉ះពាល់លើវិស័យសេដ្ឋកិច្ច"** មានគោលបំណងចែករំលែកព័ត៌មាន និងបង្កើនការយល់ដឹងអំពីគ្រោះថ្នាក់នៃអំពើហិង្សាដែលមានទំនាក់ទំនង និងប៉ះពាល់ សេដ្ឋកិច្ចក្នុងគ្រួសារ ព្រមទាំងចែករំលែកនូវចំណេះដឹងអំពី យន្តការក្នុងការដោះស្រាយបញ្ហាអំពើហិង្សា ដែលមានប្រសិទ្ធិភាព។

## អ្នកចូលរួម

វេទិកាសាធារណៈនេះរំពឹងថានឹងមាននិស្សិតប្រមាណ ២០០នាក់ មកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងសាកលវិទ្យាល័យនានានៅក្នុងទីក្រុងភ្នំពេញចូលរួម រួមទាំងមហាជនដែលមានចំណាប់អារម្មណ៍ចង់ចូលរួម ចែករំលែក និងស្វែងយល់អំពី ប្រធានបទនេះ។ ក្នុងនោះដែលយើងនឹងអញ្ជើញវាគ្មិនដែលមានបទពិសោធន៍ ធ្វើការងារជាមួយបញ្ហាយេនឌ័រ បញ្ហាអំពើហិង្សាក្នុងគ្រួសារ និងយន្តការនៃការអនុវត្តដើម្បីចូលរួមធ្វើបទបង្ហាញ និង ចែករំលែកផងដែរ។

**ទីកន្លែង៖** សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (អគារ A បន្ទប់ ០០១)

**ពេលវេលា៖** ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ចាប់ពីម៉ោង ៨:០០ -១១:០០ ព្រឹក

## របៀបវារៈ

| ម៉ោង | សកម្មភាព | អ្នកទទួលខុសត្រូវ |
|---|---|---|
| ៧:៣០ - ៨:០០ | ការអញ្ជើញមកដល់របស់អ្នកចូលរួម និងចុះវត្តមាន | និស្សិតស្ម័គ្រចិត្ត |
| ៨:០០ - ៨:០៥ | កិច្ចស្វាគមន៍ | លោកស្រី រស់ សុភាព នាយិកាអង្គការ យេនឌ័រ និង អភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) |
| ៨:០៥ - ៨:១០ | មតិសំណេះសំណាល និងប្រកាសបើកវេទិកាសាធារណៈ | មហាវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៨:១០ - ៨:៣០ | **វគ្គទី១ ៖ អំពើហិង្សា និងផលប៉ះពាល់លើសេដ្ឋកិច្ចគ្រួសារ**<br>១. បទបង្ហាញ អ្វីជាអំពើហិង្សា និងច្បាប់អំពើហិង្សា | តំណាងអង្គការអាដហុក |
| ៨:៣០ - ៩:០០ | ២. បទបង្ហាញផលប៉ះពាល់នៃអំពើហិង្សាលើសេដ្ឋកិច្ចក្នុងគ្រួសារ និងយន្តការសំរាប់ដោះស្រាយ | តំណាងក្រសួងកិច្ចការនារី |
| ៩:០០ - ៩:២០ | ៣. វេទិកាសំណួរ-ចម្លើយ រវាងវាគ្មិនកិត្តិយស និងអ្នកចូលរួម | វាគ្មិន |
| ៩:២០ - ៩:៣៥ | **សម្រាកអាហារសម្រន់** | |
| ៩:៣៥ - ១០:០៥ | **វគ្គទី២ ៖ ដំណោះស្រាយអំពើហិង្សា និងការលើកកំពស់សេដ្ឋកិច្ចគ្រួសារ**<br>១. បទបង្ហាញពីគំរោងពង្រឹងអំណាចសេដ្ឋកិច្ចស្ត្រីរបស់ GADC និង Heifer | តំណាងអង្គការ Heifer |
| ១០:០៥ - ១០:៣០ | ២. ករណីសិក្សា ការកែប្រែពីអំពើហិង្សា មកការលើកស្ទួយសេដ្ឋកិច្ចគ្រួសារ | ប្រជាពលរដ្ឋ |
| ១០:៣០ - ១០:៥០ | ៣. វេទិកាសំណួរ-ចម្លើយ រវាងវាគ្មិនកិត្តិយស និងអ្នកចូលរួម | វាគ្មិន |
| ១០:៥០ - ១០:៥៥ | ការបញ្ចេញមតិយោបល់ពីអ្នកចូលរួម | តំណាងអ្នកចូលរួម |
| ១០:៥៥ - ១១:០០ | មតិបូកសរុប និងបិទវេទិកាសាធារណៈ | តំណាងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ |

*សូមរក្សាសិទ្ធិក្នុងការកែប្រែកម្មវិធីក្នុងករណីចាំបាច់!*